Minnesota Department of Health

# ការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង

## តើការពិនិត្យល្អិតល្អន់រករោគរបេងឆ្លងជាអ្វី?

កាលណាអ្នកណាម្នាក់មានរោគ TB (របេង)សកម្ម នោះវាមានសារៈសំខាន់ណាស់ ដើម្បីឲ្យដឹងថារោគនោះបានរាលដាលទៅមនុស្សឯទៀតឬអត់។ កាលណាអ្នកធ្វើការខាងសុខភាពសាធារណៈ រកមើលក្រែងលោរោគនេះ បានឆ្លងរាលដាល នោះគេហៅថា ការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង ។

មនុស្សកើតរោគរបេង អាចចំឡងរោគទៅគេឯងដោយមិនដឹងខ្លួនឡើយ ។ បើសិនជារោគរបេងបានឆ្លងទៅមនុស្សដទៃទៀត នោះគេនឹងត្រូវការថ្នាំពេទ្យ ប្រយោជន៍កុំឲ្យគេឈឺថ្កាត់ដោយសាររោគនេះ ។

ពត៌មានដែលអ្នកផ្តល់ទៅឲ្យអ្នកធ្វើការខាងសុខភាពសាធារណៈ នៅក្នុងកំឡុងពេលការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង គឺជាការលាក់ការណ៍ ។ ភាពឯកជនរបស់អ្នកនឹងតែងតែបានការពារជានិច្ច ។

## តើមានអ្វីកើតឡើងក្នុងការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង?

អ្នកធ្វើការខាងសុខភាពសាធារណៈ នឹងសួរអ្នកពីពេលវេលាដែលអ្នកចាប់ផ្តើមក្អក ឬមិនស្រួលខ្លួន ។ សូមព្យាយាមគិតអំពីមនុស្ស**ទាំងអស់** ដែលអ្នកបានចំណាយពេលជាមួយ រួមទាំងមនុស្សរស់នៅក្នុងផ្ទះរបស់អ្នក អ្នកមកលេង ក្មេងៗ មិត្តភ័ក្តិ អ្នកធ្វើការជាមួយ អ្នករៀនក្នុងថ្នាក់ជាមួយ និងអ្នកមើលកូនឲ្យ ។ សូមសារឡើងវិញពីច្រើនអាទិត្យ ឬជាច្រើនខែកន្លងទៅ មកទល់នឹងពេលដែលអ្នកចាប់ផ្តើមឈឺ ឬបានចាប់ផ្តើមក្អក ។ រួចមកអ្នកធ្វើការខាងសុខភាពសាធារណៈ នឹងសំរេចថាអ្នកណានឹងត្រូវការពិសោធន៍រោគរបេងឬអត់ ។

**អ្វីៗដែលអ្នកប្រាប់ទៅអ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក គឺជាពត៌មានសំងាត់ ។** អ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក នឹង**មិន**ប្រាប់នរណាម្នាក់ នូវឈ្មោះ ឬពត៌មានអំពីរូបអ្នកសោះឡើយ លុះត្រាតែអ្នកថាមិនជាថ្វីទេ ។ នេះមានសេចក្តីថា អ្នកអាចប្រាប់ទៅអ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នកដោយស្មោះត្រង់ ។

អ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក អាចនឹងឆែកមើលខ្យល់ចេញចូលក្នុងផ្ទះរបស់អ្នក ឬនៅកន្លែងផ្សេងៗទៀតដែលអ្នកបានអាស្រ័យនៅ ។ ការនេះនឹងជួយសំរេចថាអ្នកណាគួរតែពិសោធរោគរបេង ។

អ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក នឹងរៀបចំមនុស្សទាំងនោះឲ្យជោះស្បែកពិសោធរោគរបេង ប៉ុន្តែគេនឹងមិនប្រាប់ថាអ្នកណាកើតរោគរបេងទេ ។ មនុស្សដែលបានចំណាយពេលច្រើនជាងគេជាមួយអ្នក នឹងបានពិសោធមុនគេ ។

ការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង ប្រើពេលយូរ ។ អ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក ចង់ធ្វើឲ្យប្រាកដថាមនុស្សណាត្រូវការ អាច

បានពិសោធមើល ។ ដោយសារហេតុនេះហើយ បានជាអ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក អាចនឹងសួរសំណួរអ្នកលើសពីម្តង ។ គេអាចនឹងសួរសំណួរអ្នកខ្លះដែលខុសពីមុន នៅពេលក្រោយទៀត ។ ការនេះគឺប្រយោជន៍ឲ្យគេអាចយល់ពត៌មានទាំងអស់។ **សូមចាំថា អ្វីៗដែលអ្នកប្រាប់ទៅអ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក គឺជាពត៌មានសំងាត់ ។**

## តើមនុស្សកើតរោគរបេងដោយរបៀបណា?

**មនុស្សគ្រប់ៗរូបអាចកើតរោគរបេង ។** កាលណាមនុស្សឈឺដោយមានរោគរបេងក្នុងសួតរបស់គេ នោះគេក៏ក្អកឬកណ្តាស់ ហើយគេអាចបញ្ចេញមេរោគរបេងដ៏តូចទៅក្នុងខ្យល់អាកាស ។



បើអ្នកចំណាយពេល នៅជិតដិតនឹងនរណាម្នាក់ដែលឈឺដោយមានរោគរបេងក្នុងសួតរបស់គេ នោះអ្នកអាចដកដង្ហើមស្រូបមេរោគរបេងរបស់គេចូលទៅក្នុងសួតរបស់អ្នក ។ បែបនេះហើយដែលអ្នកអាចកើតរោគរបេង។

អ្នកពុំអាចកើតរោគរបេងដោយសារការចាប់ដៃគ្នា ឬពីសំលៀកបំពាក់ ម្ហូបអាហារ ចានក្បាន ឬដោយសារការប៉ះពាល់នឹងវត្ថុអ្វីមួយឡើយ ។

> **សព្វថ្ងៃនេះមានថ្នាំពេទ្យល្អៗ ដើម្បីព្យាបាលរោគរបេងមិនទាន់ចេញមុខ និងរោគរបេងសកម្ម ។**

## តើរោគរបេងមិនទាន់ចេញមុខ និងរបេងសកម្ម ខុសគ្នាយ៉ាងណា?

កាលណាមេរោគរបេងចូលទៅក្នុងខ្លួន តាមធម្មតាវា "ដេកលក់"។ នេះគេហៅថា **"រោគរបេងមិនទាន់ចេញមុខ" (Latent TB Infection)** ឬហៅកាត់ថា **"LTBI"** ។ មេរោគរបេង "កំពុងដេកលក់" គឺមិនធ្វើទុក្ខរូបកាយរបស់អ្នក ឬធ្វើឲ្យអ្នកឈឺថ្កាត់ទេ ។ LTBI អាចនៅក្នុងខ្លួនជាយូរឆ្នាំ ។ ការជោះស្បែកពិសោធរោគរបេង (ម៉ានទូក្ស Mantoux) អាចប្រាប់ថាតើមានមេរោគរបេងនៅក្នុងខ្លួនរបស់អ្នកឬអត់ ។

**"រោគរបេងសកម្ម"(Active TB Disease)** គឺជាពេលដែលមេរោគរបេង "ភ្ញាក់" ហើយចាប់ផ្តើមដុះដាលឡើង និងធ្វើទុក្ខខ្លួនប្រាណអ្នក ។ មនុស្សដែលកើតរោគរបេងសកម្ម អាចឈឺថ្កាត់ខ្លាំងណាស់ ។ សញ្ញារោគរបេងគឺក្អក់ឥតបាត់ ស្រកទំងន់ បរិភោគពុំសូវបាន បែកញើសនៅពេលយប់ គ្រុន

# ការពិនិត្យល្អិតល្អន់ រករោគរបេងឆ្លង – ទំព័រទី 2

និងឈឺក្នុងដើមទ្រូងរបស់អ្នក ។ បើរោគរបេងឋិតនៅក្នុងសួតរបស់គេ នោះវាអាចឆ្លងរាលដាលទៅមនុស្សផ្សេងៗទៀតបាន ។

ប្រហែល១០ភាគរយនៃមនុស្សកើតរោគរបេង LTBI បង្កើតទៅជា**រោគរបេងសកម្ម** ។ បើសិនជាអ្នកមានបញ្ហាសុខភាពអ្វីផ្សេងទៀត នោះការគ្រោះថ្នាក់នឹងរោគនេះកាន់តែខ្លាំងឡើង ។

**បើសិនជាខ្ញុំមានរោគរបេងសកម្ម តើខ្ញុំអាចការពារមិត្តភ័ក្តិ និងគ្រួសាររបស់ខ្ញុំដោយរបៀបណា?**
មានការបួនយ៉ាងដ៏សំខាន់ ដែលអ្នកគួរតែធ្វើ គឺ :

1. **ត្រូវលេបថ្នាំរបេងរបស់អ្នកដូចបានបង្គាប់ ។** កាលណាអ្នកចាប់ផ្តើមលេបថ្នាំរបេងរបស់អ្នក នោះគ្រូពេទ្យរបស់អ្នកនឹងពិសោធមើលថាតើថ្នាំពេទ្យនោះមានប្រសិទ្ធិភាពល្អជាយ៉ាងណា ។ កាលណាថ្នាំពេទ្យបានសំឡាប់មេរោគរបេងគ្រប់គ្រាន់ហើយ នោះអ្នកក៏នៅតែបន្តលេបថ្នាំទៀត ប៉ុន្តែអ្នកលែងអាចចំឡងមេរោគរបេងទៅគេទៀត ។
2. ទំរាំអ្នកលែងអាចចំឡងមេរោគរបេងទៀត នោះអ្នក**ត្រូវតែបាំងមាត់របស់អ្នកជានិច្ច ដោយប្រើក្រដាសជូតស្តើងៗ នៅពេលអ្នកក្អក** ។
3. អ្នកធ្វើការខាងសុខភាពសារធារណៈរបស់អ្នក នឹងប្រាប់ពីការអ្វីៗដែលអ្នកអាចធ្វើ ដើម្បីជៀសវាងនូវការចំឡងមេរោគរបេងទៅមនុស្សផ្សេងៗទៀត ។
    - អ្នកអាចនឹងត្រូវនៅឲ្យឆ្ងាយពីទីកន្លែងសាធារណៈ ពីកន្លែងធ្វើការ និងនៅឲ្យឆ្ងាយពីសាលារៀន ។
    - អ្នកអាចនឹងត្រូវហាមឃាត់អ្នកមកសួរសុខទុក្ខ(លេង) កុំឲ្យមកផ្ទះរបស់អ្នក ។
4. **សូមជួយអ្នកធ្វើការខាងសុខភាពសាធារណៈរបស់អ្នក ជាមួយការពិនិត្យល្អិតល្អន់រករោគរបេងឆ្លង ។** អ្នកធ្វើការខាងសុខភាពសាធារ-ណៈរបស់អ្នក ចង់រក្សាគ្រួសារនិងមិត្តភ័ក្តិរបស់អ្នក ឲ្យមានសុខភាពល្អ និងផុតពីគ្រោះថ្នាក់ដោយសាររោគរបេង ។

**បើសិនជាមនុស្សដែលខ្ញុំស្គាល់ មានរោគរបេងសកម្មក្នុងសួត តើខ្ញុំគួរគប្បីដឹងអំពីអ្វីខ្លះ?**
បើអ្នកបានចំណាយពេលយ៉ាងច្រើនជាមួយមនុស្សណាម្នាក់ ដែលមានរោគរបេងសកម្ម នោះអ្នកអាចដកដង្ហើមចូលមេរោគរបេងទៅក្នុងខ្លួនរបស់អ្នក ម្ល៉ោះហើយការពិសោធន៍ររោគរបេង គឺសំខាន់សំរាប់អ្នកណាស់ ។

បើអ្នកត្រូវការ ក្រសួងសុខភាពសាធារណៈរបស់អ្នក នឹងរៀបចំឲ្យអ្នកទទួលការជោះស្បែកពិសោធ (ម៉ានទូក្សតេស្ត Mantoux Test) ដោយឥតគិតថ្លៃ។

បើម៉ានទូក្សតេស្តរបស់អ្នកគឺជា **"អវិជ្ជមាន"** (ធម្មតា) នោះអ្នកប្រហែលជាគ្មានមេរោគរបេងនៅក្នុងខ្លួនរបស់អ្នកទេ ។ ដើម្បីឲ្យប្រាកដអំពីការនេះ អ្នកអាចនឹងត្រូវការពិសោធន៍ម្តងទៀត នៅប៉ុន្មានអាទិត្យក្រោយមក ។

បើម៉ានទូក្សតេស្តរបស់អ្នកគឺជា **"វិជ្ជមាន"** នោះអ្នកមានរោគរបេងនៅក្នុងខ្លួនរបស់អ្នកហើយ ។ អ្នកនឹងត្រូវការទៅជួបគ្រូពេទ្យ និងថតសួតដោយកាំរស្មីអិច ដើម្បីឲ្យដឹងថាអ្នកមានរោគរបេងមិនទាន់ចេញមុខ (LTBI) ឬមានរោគរបេងសកម្ម ។ បើសិនជាអ្នកមានរោគ LTBI នោះវាជាការសំខាន់ណាស់ ដែលអ្នកត្រូវការ លេបថ្នាំពេទ្យ ដើម្បីសំឡាប់មេរោគរបេង ។

កូនតូចៗរបស់អ្នក ឬមនុស្សកើតរោគ HIV ឬមានបញ្ហាសុខភាពអ្វីមួយ គឺទំនងនឹងកើតរោគរបេងសកម្ម ខ្លាំងជាងមនុស្សផ្សេងៗទៀត ។ គេអាចនឹងត្រូវការលេបថ្នាំពេទ្យ ទោះបើម៉ានទូក្សតេស្តរបស់គេជាអវិជ្ជមានក្តី ។

បើសិនជាអ្នកមានសញ្ញារោគរបេង (ក្អក់ឥតបាត់ ស្រកទំងន់ បែកញើសនៅពេលយប់ បរិភោគអាហារពុំសូវបាន គ្រុន ឬឈឺដើមទ្រូង) អ្នកគួរតែទៅជួបគ្រូពេទ្យ ទោះបើម៉ានទូក្សតេស្តរបស់អ្នកជាអវិជ្ជមានក៏ដោយ ។

**តើខ្ញុំគួរតែធ្វើអ្វី បើសិនជាលទ្ធផលម៉ានទូក្សតេស្តជាវិជ្ជមានរួចហើយ?**
បើសិនជាអ្នកមានកំណត់ត្រាអ្វី បញ្ជាក់ថាអ្នកធ្លាប់បានធ្វើម៉ានទូក្សតេស្ត ហើយមានលទ្ធផលជាវិជ្ជមាន នោះអ្នកមិនចាំបាច់ធ្វើម្តងទៀតនៅឥឡូវនេះទេ ។ បើអ្នកពុំមានកំណត់ត្រាទេ អ្នកនឹងត្រូវការធ្វើម្តងទៀត ។ ការធ្វើនេះ នឹងពុំមានគ្រោះថ្នាក់អ្វីដល់អ្នកឡើយ ។

**ចុះតើថ្នាំ BCG ចាក់ការពារ វិញនោះ ជាយ៉ាងណាដែរ?**
ថ្នាំ BCG មិនតែងតែការពារអ្នកកុំឲ្យកើតរោគរបេងនោះឡើយ ។ ថ្នាំ BCG មិនមែនតែងតែបណ្តាលឲ្យការធ្វើម៉ានទូក្សពិសោធន៍មានលទ្ធផលជាវិជ្ជមាននោះឡើយ ។ បើអ្នកធ្លាប់បានចាក់ថ្នាំ BCG ក៏វាមិនគ្រោះថ្នាក់អ្វីដល់អ្នកដើម្បី ធ្វើម៉ានទូក្សតេស្តនោះទេ ។

MINNESOTA MDH DEPARTMENT OF HEALTH

Tuberculosis Prevention and Control Program
P.O. Box 64975
St. Paul, MN 55164-0975
651-201-5414
1-877-676-5414
www.health.state.mn.us/tb

6/2005